# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាមិនកម្មវិធីបូជនីយេសក៍
# តាំងគោក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៩
# សក្ខីភាពអំពីជីវិត

**អត្ថបទទី១៖ នេហេមី ៨,២-៤ក.៥-៦.៨-១០**

ចូរនាំគ្នាត្រឡប់ទៅពិសាសាច់ និងស្រាដ៏ឆ្ងាញ់ៗ ហើយយកមួយចំណែកឲ្យអស់អ្នកដែលមិនទាន់រៀបចំបរិភោគនោះផង ដ្បិតថ្ងៃនេះ ជាថ្ងៃដ៏សក្ការៈថ្វាយព្រះអម្ចាស់នៃយើង មិនត្រូវកើតទុក្ខព្រួយឡើយ ព្រោះអំណរដែលមកពីព្រះអម្ចាស់ ជាកម្លាំងរបស់អ្នករាល់គ្នា។ នហ ៨,១០

**អត្ថបទទី២៖ កូរិនថូសទី១ ១២,១២-៣០**

ព្រះគ្រីស្ត*ប្រៀបបានទៅនឹងរូបកាយមួយ ដែលចែកចេញជាច្រើនផ្នែក។ ទោះបីមានសរីរាង្គច្រើនយ៉ាងណាក៏ដោយ ក៏សរីរាង្គទាំងអស់ផ្សំគ្នាជារូបកាយតែមួយដែរ។ ១ករ ១២,១២

**ដំណឹងល្អ៖ លក ១,១-៤ ៤,១៤-២១**

អស់អ្នកដែលបានឃើញផ្ទាល់នឹងភ្នែក តាំងពីដំបូងរៀងមក ហើយទទួលមុខងារបម្រើព្រះបន្ទូល បានរៀបរាប់ហេតុការណ៍ទាំងនោះបន្តមកយើងខ្ញុំ។ លក ១,២

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងបានស្ដាប់គម្ពីររបស់លោកលូកា ដែលគាត់បានកត់ត្រាទុកអ្វីដែលគាត់បានស្ដាប់ ដើម្បីជ្រាបដល់លោក ថេអូភីល និងមនុស្សផ្សេងៗទៀតឲ្យគេដឹងថាអ្វីៗទាំងអស់ដែលព្រះយេស៊ូបាននិយាយពីដើម ចាប់ផ្ដើមសរសេរខ្លះៗនៅក្នុងសៀវភៅវាជាសេចក្ដីពិតហើយ។ នៅថ្ងៃដែលព្រះយេស៊ូចាប់ផ្ដើមប្រកាសដំណឹងល្អ នៅសម័យនោះគ្មានវីដេអូ គ្មានម៉ាស៊ីនថតសម្លេង គ្មានអ្វីដើម្បីរក្សាទុកបានទេ។ ប៉ុន្តែ គេចាំពីមួយថ្ងៃទៅមួយថ្ងៃអ្វីដែលព្រះយេស៊ូមានព្រះបន្ទូល ក្រោយមកគេចាប់ផ្ដើមកត់ត្រា ដោយសារគេនឹកឃើញឥឡូវនេះព្រះយេស៊ូសោយទិវង្គតហើយ ព្រះអង្គលែងគង់នៅជាមួយយើង ប៉ុន្តែអ្វីដែលព្រះយេស៊ូបានថ្លែងសំខាន់ណាស់។ សម្រាប់មរណសាក្សីយើងក៏ដូចគ្នាដែរ យើងឥតមាននរណាដែលជាសាក្សីបន្ទាល់ដែលនៅរស់សព្វថ្ងៃ។ យើងបានពូតាមគេដល់ពេលវេលាយើងរៀបចំឯកសារដើម្បីទុក ដើម្បីទទួលកម្លាំងនៅក្នុងជំនឿរបស់យើង និងដើម្បីយល់ថាដូចព្រះបន្ទូលរបស់ព្រះយេស៊ូដែលយើងបានស្ដាប់សព្វថ្ងៃ ដូចជីវិតរបស់ព្រះសហាគមន៍កាតូលិកនៅប្រទេសកម្ពុជា ជាកម្លាំងមួយដើម្បីឲ្យយើងរស់នៅជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈ មានព្រះបន្ទូលដែលចិញ្ចឹមជីវិតយើង ដែលមានប្រវត្តិសាស្ត្រដែលបំភ្លឺយើង។

**ព្រះបន្ទូលចិញ្ចឹមជីវិតយើង** ដោយសារព្រះបន្ទូលរបស់ព្រះយេស៊ូពីមួយថ្ងៃទៅមួយថ្ងៃ ណែនាំឲ្យយើងទទួលពន្លឺនៅក្នុងជីវិតរបស់យើង។ នៅពេលយើងចូលអភិបូជាម្តងៗ យើងយកព្រះបន្ទូលរបស់ព្រះយេស៊ូមកអនុវត្តតាម "**ចូរស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបានស្រឡាញ់យើង**"។ ពាក្យនេះព្រះយេស៊ូមានព្រះបន្ទូល នៅពេលព្រះអង្គកំពុងចែកមរកតរបស់ព្រះអង្គ មុនព្រះយេស៊ូសោយទិវង្គត គឺព្រះអង្គមានព្រះបន្ទូលពេជ្រដើម្បីចែកដល់ក្រុមគ្រីស្តទូត។

**ប្រវត្តិសាស្ត្រដើម្បីបំភ្លឺយើង** រឿងព្រះយេស៊ូជាង២០០០ឆ្នាំនៅស្រុកកាលីឡេ ប៉ុន្តែប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍និងរមណសាក្សីកម្ពុជាយើងគឺតែប៉ុន្មានឆ្នាំមុន ដោយដឹងថាយើងមានគ្រីស្តបរិស័ទមួយចំនួនដែលរស់នៅសព្វថ្ងៃ ដែលបានឆ្លងទុក្ខលំបាក ដែលបានឆ្លងប្រវត្តិសាស្ត្រដ៏ងងឹត ដើម្បីសព្វថ្ងៃទៅជាសាក្សី។ សូមគិត **តើអ្នកណាធ្លាប់មានឥទ្ធិពលលើជីវិតរបស់យើងសព្វថ្ងៃដើម្បីឲ្យខ្ញុំដើរតាមព្រះយេស៊ូ?** យើងបានកែប្រែចិត្តគំនិតថ្មីៗដើម្បីធ្វើជាគ្រីស្តបរិស័ទ យើងគិតដែរថា **តើអ្នកណាដែលបានធ្វើជាសាក្សីដើម្បីឲ្យខ្ញុំស្គាល់ព្រះយេស៊ូ?** ដែលសាក្សីនេះបានទទួលព្រះបន្ទូលពីសាក្សីមួយទៀតដែលបន្តៗគ្នា រហូតដល់លោកអភិបាល ឆ្មារ សាឡាស់ លោកឪពុក ឆ្មារ សាឡឹម លោកឪពុក សម្រើន...។ យើងកំពុងភ្ជាប់ជាមួយបងប្អូនដែលជាប្រវត្តិសាស្ត្ររបស់យើង ដែលជាមូលដ្ឋានគ្រឹះរបស់យើងដើម្បីឲ្យយើងទៅមុខ។ សព្វថ្ងៃយើងទាំងអស់គ្នា យើងត្រូវការធ្វើយ៉ាងណាដើម្បីរស់នៅជាគ្រីស្តបរិស័ទនៅក្នុងសតវត្សរ៍ទី២១ ដើម្បីប្រកាសដំណឹងល្អយ៉ាងសមរម។

ពេលយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ យើងនឹកឃើញមនុស្សយើងមានតម្លៃថ្លៃថ្នូរដ៏សក្ការៈបំផុត។ នៅពេលយើងបង្កើតទំនាក់ទំនងដើម្បីជួយបងប្អូនឯទៀតៗ ឲ្យយើងគិតអំពីផលប្រយោជរួម។ សាមគ្គីភាព ដើម្បីអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូ "**ស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**" ឲ្យយើងចេះបង្កើតសាមគ្គីភាពរវាងគ្នានឹងគ្នា។ សព្វថ្ងៃ យើងអាត្មានិយមណាស់ ប៉ុន្តែសាមគ្គីភាពណែនាំឲ្យយើងបើកចិត្តគំនិតទូលំទូលាយ ដើម្បីបង្កើតទំនាក់ទំនងនៅក្នុងសង្គមបច្ចុប្បន្ននេះ។ នៅពេលយើងរស់នៅឲ្យយើងចេះបើកភ្នែក បើកត្រចៀក មើលឃើញ ស្តាប់លឺ សេចក្តីត្រូវការរបស់អ្នកជិតខាង។ នៅក្នុងព្រះសហគមន៍ កុំឲ្យយើងអាត្មានិយមគិតតែក្រុមយើង សង្គហៈជួយតែគ្នាយើង ឲ្យយើងបង្កើតកម្មវិធីថែមទៀតដើម្បីជួយអ្នកក្រីក្រ ជួយជនពិការ ចាស់ជរា...។ ធ្វើយ៉ាងណាឲ្យព្រះសហគមន៍របស់យើងមានសញ្ញាសម្គាល់ពិសេស តាមព្រះយេស៊ូមានព្រះបន្ទូលជាក់ស្តែង "**មនុស្ស**

**ដែលខ្វាក់មើលឃើញ មនុស្សដែលថ្លង់ស្តាប់ឮ...**"។ យើងធ្វើយ៉ាងណាដើម្បីឲ្យព្រះសហគមន៍យើងបង្កើតសាមគ្គីភាពយ៉ាងទូលំទូលាយ ដោយសារសេចក្តីត្រូវការនៅក្នុងសង្គមរបស់យើងច្រើនណាស់ ពេលឥតមានសាលា ពេលឥតមានផ្ទះ ពេលឥតមានដី ពេលឥតមានលុយ...។

គោលការជំនួស គឺបងៗជួយប្អូនៗ យើងមានលោកអភិបាល ឆ្មារ សាឡាស់ នៅទីនេះជាបងរបស់យើងដែលបានជួយឲ្យព្រះសហគមន៍មានជីវិតសព្វថ្ងៃ។ បងមានសមត្ថភាព ដើម្បីជួយប្អូនឲ្យដើរបាន មិនមែនធ្វើជំនួសតែណែនាំឲ្យប្អូនៗអាចធ្វើអ្វីដែលបងៗធ្វើបាន។ ខ្ញុំសុំឲ្យគ្រប់ព្រះសហគមន៍ មានក្រុមចម្រៀងឲ្យច្បាស់ យើងត្រូវការបង្រៀនយុវជនយុវនារីដើម្បីឲ្យចេះលេងភ្លេង ចេះច្រៀង ព្រោះពួកគេពោរពេញដោយសមត្ថភាព។ យើងត្រូវការនៅមុខដើម្បីបង្ហាញផ្លូវ យើងត្រូវការរត់ដើម្បីធ្វើដំណើរជាមួយព្រះយេស៊ូ ដើម្បីអនុវត្តតាមពាក្យរបស់សន្តប៉ូល "**ខ្ញុំកំពុងរត់ដោយមានគោលដៅទទួលរង្វាន់ ពោលគឺព្រះជាម្ចាស់បានហៅឲ្យឡើងទៅស្ថានបរមសុខតាមរយៈព្រះយេស៊ូគ្រីស្ត**"។ ជីវិតរបស់យើង មិនមែនជាជីវិតដែលអង្គុយខ្ជិល ប៉ុន្តែផ្ទុយទៅវិញឲ្យយើងឈរឡើងដើម្បីរត់ទៅមុខ ដើម្បីបង្ហាញផ្លូវដល់បងប្អូនឯទៀតៗ ដោយដឹងថានៅមុខបំផុតយើងមានព្រះយេស៊ូគ្រីស្ត ដែលណែនាំឲ្យយើងពោរពេញដោយកម្លាំងកាយកម្លាំងចិត្តថែមទៀត។

សូមចាំពាក្យទាំងនេះ ភក្តីភាព សេចក្តីស្រឡាញ់ សេចក្តីសង្ឃឹម តម្លៃថ្លៃថ្នូរ ជីវិតការចងចាំ កែប្រែចិត្តគំនិត ក្រុមគ្រួសារជាអទិភាពសំខាន់ដើម្បីរកសេចក្តីសុខសាន្ត។ ប្រសិនបើយើងរស់នៅក្នុងនេះ មានន័យថាយើងជាគ្រីស្តបរិស័ទដ៏ពេញលក្ខណៈដែលពោរពេញដោយកម្លាំង ដោយសារមរណសាក្សី ដោយសារព្រះយេស៊ូ ដើម្បីធ្វើដំណើររួមជាមួយគ្នា ឲ្យព្រះសហគមន៍កាតូលិកកម្ពុជាទៅជាព្រះសហគមន៍មួយដែលផ្តល់សក្ខីភាពអំពីជីវិត។ អាម៉ែន៕